

# តើអ្វីខ្លះនឹងកើតឡើងនៅពេលដែលកូនពិការរបស់ខ្ញុំចូលដល់អាយុ ១៨ ឆ្នាំ?

## ការគាំទ្រចំពោះការសម្រេចចិត្តរបស់មនុស្សពេញវ័យ

CPR
Center for Public Representation



# ប្រធានបទនៅថ្ងៃនេះ

- តើអ្វីខ្លះនឹងកើតឡើងនៅពេលបុគ្គលម្នាក់ចូលដល់អាយុ ១៨ ឆ្នាំ?
- តើសិទ្ធិជាអាណាព្យាបាលស្របច្បាប់លើមនុស្សពេញវ័យម្នាក់មានន័យយ៉ាងណា?
- ហេតុអ្វីគេត្រូវគិតអំពីជម្រើសផ្សេងទៀតជាមុនសិន?
- តើការសម្រេចចិត្តដែលមានការគាំទ្រមានន័យយ៉ាងណា?
- តើមានជម្រើសផ្សេងទៀតអ្វីខ្លះនៅក្នុង៖
    - វិស័យអប់រំ?
    - ការថែទាំសុខភាព?
    - ការគ្រប់គ្រងប្រាក់កាស?

# តើអ្វីខ្លះនឹងកើតឡើងនៅពេលបុគ្គលម្នាក់ចូលដល់អាយុ ១៨ ឆ្នាំ?

- នៅរដ្ឋម៉ាសាឈូសិត មនុស្សម្នាក់ក្លាយជាមនុស្សពេញវ័យស្របច្បាប់ (នីតិជន) នៅពេលគាត់ចូលដល់អាយុ ១៨ ឆ្នាំ។
- តាមច្បាប់របស់រដ្ឋនេះ ពួកគេត្រូវធ្វើការសម្រេចចិត្តដោយខ្លួនឯង ដោយមិនគិតថាបុគ្គលទាំងនោះមានពិការភាព ឬអត់នោះទេ ។
- សាលារៀនទាំងឡាយហៅដំណាក់កាលនេះថា "ការផ្ទេរសិទ្ធិ" ។



# វិធានច្បាប់សំខាន់ៗសម្រាប់ធ្វើការសម្រេចចិត្តក្នុងរដ្ឋម៉ាសាឈូសិត

- ការសម្រេចចិត្តដែលមានការគាំទ្រ
- ចែករំលែកអំណាចក្នុងការសម្រេចចិត្តទាក់ទងនឹងវិស័យអប់រំ
- លិខិតផ្ទេរសិទ្ធិសម្រេចចិត្តទាក់ទងនឹងសេវាថែទាំសុខភាព
- លិខិតផ្ទេរសិទ្ធិសម្រេចចិត្តទៅឲ្យបុគ្គលជាតំណាងដែលគេអាចប្រើការបានយូរអង្វែង
- ការប្រគល់សិទ្ធិអំណាចក្នុងការសម្រេចចិត្តទាក់ទងនឹងវិស័យអប់រំ
- បុគ្គលជាតំណាងដែលមានសិទ្ធិក្នុងការគ្រប់គ្រងប្រាក់កាស (ទាំងទទួល និងចំណាយ)
- អាណាព្យាបាល ឬអ្នកសម្រេចចិត្តជំនួសដែលតុលាការបានតែងតាំងនិងផ្តល់សិទ្ធិ



# តើលិខិតទទួលបានសិទ្ធិជាអាណាព្យាបាលស្របច្បាប់លើមនុស្សពេញវ័យម្នាក់មានន័យយ៉ាងណា?



- ខុសប្លែកពីភាពជាអាណាព្យាបាលលើកុមារម្នាក់ ។
- លិខិតទទួលបានសិទ្ធិជាអាណាព្យាបាល មានន័យថា មានតែតុលាការប៉ុណ្ណោះទើបមានសិទ្ធិតែងតាំងបុគ្គលម្នាក់ ។
- នោះគឺជាដំណើរការផ្លូវច្បាប់ដែលតុលាការសម្រេចចិត្តថា មនុស្សពេញវ័យម្នាក់ "អសមត្ថភាព" (បាត់បង់សមត្ថភាពក្នុងការសម្រេចចិត្ត) និងតែងតាំងមនុស្សម្នាក់ទៀត (ហៅថា "អាណាព្យាបាល") ដើម្បីសម្រេចចិត្តជំនួសបុគ្គលនោះ នៅលើគ្រប់កិច្ចការទាំងអស់ ឬលើកិច្ចការមួយចំនួន ។

# តើលិខិតទទួលបានសិទ្ធិជាអាណាព្យាបាល មិនរាប់បញ្ចូលអ្វីខ្លះ?



- លិខិតទទួលបានសិទ្ធិជាអាណាព្យាបាលមិនមែនជាជម្រើសតែមួយគត់ដែលគេត្រូវតែពិចារណាដើម្បីជ្រើសយកនោះទេ ។
- លិខិតទទួលបានសិទ្ធិជាអាណាព្យាបាលមិនមែនគ្រាន់តែជាក្រដាសមួយសន្លឹកនោះទេ។
- លិខិតទទួលបានសិទ្ធិជាអា ព្យាបាលមិនមែនជាការធានាសុវត្ថិភាពទេ។
- លិខិតទទួលបានសិទ្ធិជាអាណាព្យាបាលមិនមែនគ្មានគុណវិបត្តិទេ។

# តើជម្រើសអ្វីផ្សេងទៀតមានអ្វីខ្លះ?

- ការសម្រេចចិត្តដែលមានការគាំទ្រ
- ចែករំលែកអំណាចក្នុងការសម្រេចចិត្តទាក់ទងនឹងវិស័យអប់រំ
- លិខិតផ្ទេរសិទ្ធិសម្រេចចិត្តទាក់ទងនឹងសេវាថែទាំសុខភាព (Health Care Proxy)
- លិខិតផ្ទេរសិទ្ធិសម្រេចចិត្តទៅឲ្យបុគ្គលជាតំណាងដែលគេអាចប្រើការបានយូរអង្វែង (Durable Power of Attorney)
- ការប្រគល់សិទ្ធិអំណាចក្នុងការសម្រេចចិត្តទាក់ទងនឹងវិស័យអប់រំ
- បុគ្គលជាតំណាងដែលមានសិទ្ធិក្នុងការគ្រប់គ្រងប្រាក់កាស (ទាំងទទួលនិងចំណាយ) (Representative Payee)
- អាណាព្យាបាល ឬអ្នកសម្រេចចិត្តជំនួសដែលតុលាការបានតែងតាំងនិងផ្តល់សិទ្ធិ
- និងជម្រើសច្រើនទៀត!



# តើការសម្រេចចិត្តដែលមានការគាំទ្រមានន័យយ៉ាងណា?



- មនុស្សទាំងឡាយសម្រេចចិត្តដោយខ្លួនឯង ដោយមានអ្នកដទៃដែលពួកគេជ្រើសរើស និងជឿជាក់ជួយផ្តល់យោបល់ណែនាំផ្សេងៗ ។
- អ្នកគាំទ្រទាំងឡាយផ្តល់ដល់ពួកគេនូវការណែនាំ និងការជួយជ្រោមជ្រែងផ្សេងៗ ។
- ការជួយជ្រោមជ្រែងនោះអាចមានលក្ខណៈជាផ្លូវការ (មានការសរសេរជាលិខិតលាយលក្ខណ៍អក្សរ) ឬមានលក្ខណៈមិនផ្លូវការ ។
  - ឧទាហរណ៍ "កិច្ចព្រមព្រៀងស្តីពីការសម្រេចចិត្តដែលមានការគាំទ្រ"
- គេអាចកែប្រែសេចក្តីថ្លែងនៅក្នុងលិខិតនោះ ហើយគេក៏អាចផ្លាស់ប្តូរវាទៅតាមពេលវេលាដែរ ។
- គេអាចប្រើប្រាស់លិខិតនោះនៅក្នុងរដ្ឋណាក៏បាន រាប់ទាំងរដ្ឋម៉ាសាឈូសិត ។
- ពេលវេលាជួយឲ្យមនុស្សម្នាក់រៀនពង្រឹងជំនាញក្នុងការសម្រេចចិត្ត និងរៀនពីកំហុសឆ្គងនានា។

# ទស្សនវិស័យផ្ទាល់ខ្លួន



កូ ហាសាន (Hasan Ko)

# គន្លឹះមួយចំនួនសម្រាប់អនុវត្តនៅក្នុងការសម្រេចចិត្តដែលមានគាំទ្រ

មនុស្សដែលជាអ្នកផ្តល់ការគាំទ្រ ធ្វើការងារជាមួយជនពិការភាពនោះ ដើម្បីឈ្វេងយល់អំពី៖

- តើអ្វីជាគោលដៅរបស់ជនមានពិការភាពនោះ?
- តើជនមានពិការភាពនោះចង់បាន និងត្រូវការជំនួយអ្វីខ្លះ?
- តើបុគ្គលនោះចង់ជួយអ្នកណា?
- តើបុគ្គលនោះចង់ឲ្យគេជួយគាត់របៀបណា?
- តើគាត់ត្រូវការអ្វីខ្លះដើម្បីឲ្យគាត់អាចសម្រេចចិត្តដោយមានការគាំទ្រ?



# វិធានច្បាប់មួយចំនួនដែលគេអាចប្រើជាមួយ នឹងការសម្រេចចិត្តដោយមានការគាំទ្រ

- ទម្រង់បែបបទសម្រាប់អនុញ្ញាតឲ្យគេចែកចាយព័ត៌មានផ្ទាល់ខ្លួន (Release of Information Forms)
- លិខិតផ្ទេរសិទ្ធិសម្រេចចិត្តទាក់ទងនឹងសេវាថែទាំសុខភាព (Health Care Proxy)
- លិខិតផ្ទេរសិទ្ធិសម្រេចចិត្តទៅឲ្យបុគ្គលជាតំណាងដែលគេអាចប្រើការបានយូរអង្វែង (Durable Power of Attorney)



# ការវាយតម្លៃអំពីការយល់ដឹង



## ពិតឬមិនពិត

ច្បាប់របស់រដ្ឋម៉ាសាឈូសិត ចែងថា ឪពុកម្តាយបង្កើតគឺជាអាណាព្យាបាលស្របច្បាប់លើកូនរបស់ពួកគាត់ដែលមានពិការភាពនោះដោយស្វ័យប្រវត្តិ នៅពេលដែលកូននោះចូលដល់អាយុ ១៨ ឆ្នាំ។



# ការវាយតម្លៃអំពីការយល់ដឹង

**មិនពិត**

ការពិត - ច្បាប់របស់រដ្ឋ ម៉ាសាឈូសិត ចែងថាឪពុកម្ដាយបង្កើតមិនមែនជាអាណាព្យាបាលស្របច្បាប់លើកូនរបស់ពួកគាត់ដែលមានពិការភាពនោះដោយស្វ័យប្រវត្តិទេ នៅពេលដែលកូននោះចូលដល់អាយុ ១៨ ឆ្នាំ។

# ការវាយតម្លៃអំពីការយល់ដឹង



## ពិតឬមិនពិត

ឪពុកម្តាយត្រូវតែដាក់ពាក្យសុំសិទ្ធិធ្វើជាអាណាព្យាបាលស្របច្បាប់ នៅពេលដែលកូនរបស់គាត់ដែលមានពិការភាព ចូលដល់អាយុ ១៨ ឆ្នាំ។

# ការវាយតម្លៃអំពីការយល់ដឹង



## មិនពិត

ការពិត - ច្បាប់មិនបានចែងថាឪពុកម្តាយត្រូវតែដាក់ពាក្យសុំសិទ្ធិធ្វើជាអាណាព្យាបាលស្របច្បាប់ទៅលើកូនរបស់ពួកគាត់ នៅពេលដែលកូនរបស់ពួកគាត់ដែលមានពិការភាពនោះ ចូលដល់អាយុ ១៨ ឆ្នាំ។ ឪពុកម្តាយ និងមនុស្សជាទីស្រលាញ់របស់បុគ្គលដែលមានពិការភាពនោះគួរពិចារណាគ្រប់ជម្រើសដែលពួកគេមាន ។

# ការវាយតម្លៃអំពីការយល់ដឹង



## ពិតឬមិនពិត

គេអាចពិបាកផ្លាស់ប្តូរ ឬបញ្ឈប់សិទ្ធិជាអាណាព្យាបាលស្របច្បាប់ ។



# ការវាយតម្លៃអំពីការយល់ដឹង

## ពិត

គេអាចពិបាកផ្លាស់ប្តូរ ឬបញ្ឈប់សិទ្ធិស្របច្បាប់ជាអាណាព្យាបាល ។

# ការវាយតម្លៃអំពីការយល់ដឹង



## ពិតឬមិនពិត

បន្ទាប់ពីមនុស្សម្នាក់ចូលដល់អាយុ ១៨ ឆ្នាំ វេជ្ជបណ្ឌិតអាចនិយាយជាមួយឪពុកម្តាយរបស់បុគ្គលនោះបាន ប្រសិនបើឪពុកម្តាយរបស់គាត់ទទួលបានសិទ្ធិស្របច្បាប់ធ្វើជាអាណាព្យាបាលរបស់គាត់ ។



# ការវាយតម្លៃអំពីការយល់ដឹង

## មិនពិត

ការពិត - បន្ទាប់ពីមនុស្សម្នាក់ចូលដល់អាយុ ១៨ ឆ្នាំ វេជ្ជបណ្ឌិតអាចនិយាយជាមួយឪពុកម្ដាយរបស់គាត់បន្ទាប់ពីបានការអនុញ្ញាតពីបុគ្គលនោះ ។

# ការវាយតម្លៃអំពីការយល់ដឹង



## ពិតឬមិនពិត

ការសម្រេចចិត្តរបស់ជនពិការដោយមានគាំទ្រពីអាណាព្យាបាល អាចត្រូវបានធ្វើឡើងដោយមិនចាំបាច់មានមេធាវីធ្វើជាតំណាង ឬត្រូវទៅតុលាការទេ ។

# ការវាយតម្លៃអំពីការយល់ដឹង



## ពិត

ការសម្រេចចិត្តរបស់ជនពិការភាពដោយមានគាំទ្រពីអាណាព្យាបាល អាចត្រូវបានធ្វើឡើងដោយមិនចាំបាច់មានមេធាវីធ្វើជាតំណាងឬត្រូវទៅតុលាការទេ ។

# តើមានជម្រើសផ្សេងទៀតអ្វីខ្លះនៅក្នុងវិស័យអប់រំ?



- ការសម្រេចចិត្តដែលមានការគាំទ្រ
  - ទម្រង់បែបបទសម្រាប់អនុញ្ញាតឲ្យគេបញ្ចេញព័ត៌មានផ្ទាល់ទាក់ទងនឹងកំណត់ត្រានៅក្នុងវិស័យអប់រំ ("FERPA" Release of Information Form)
- ចែករំលែកជាមួយមនុស្សពាក់ព័ន្ធនូវការសម្រេចចិត្តទាក់ទងនឹងវិស័យអប់រំ
- ផ្ទេរសិទ្ធិទៅមនុស្សពាក់ព័ន្ធនូវការសម្រេចចិត្តទាក់ទងនឹងវិស័យអប់រំ

*FERPA = The Family Education Rights and Privacy Act of 1974*

# សេណារីយ៉ូទី ១

អរុណ ទើបតែមានអាយុ ១៨ ឆ្នាំ ។ គាត់មានពិការភាពខាងសតិបញ្ញា ហើយគាត់នឹងទទួលសេវាផ្នែកការអប់រំពិសេស តាមរយៈសាលារៀនរបស់គាត់រហូតដល់គាត់មានអាយុ ២២ ឆ្នាំ ។ ទោះបីឪពុកម្តាយរបស់អរុណចង់ឲ្យអរុណមានបទពិសោធន៍ក្នុងការសម្រេចចិត្តដោយខ្លួនឯងក៏ដោយ ក៏ពួកគាត់នៅតែបារម្ភថាសាលារៀននឹងឈប់ចែករំលែកព័ត៌មានរបស់អរុណជាមួយពួកគាត់ទៀត ព្រោះសព្វថ្ងៃនេះអរុណជាមនុស្សពេញវ័យ (នីតិជន) ។ ពួកគាត់ត្រូវការព័ត៌មានទាំងនោះដើម្បីជួយអរុណឱ្យយល់ដឹងអំពីជីវិតប្រចាំថ្ងៃនៅក្នុងសាលារៀន និងដើម្បីជួយអរុណឲ្យគិតថា តើអរុណត្រូវស្នើសុំសេវាបន្ថែមទាក់ទងនឹងវិស័យអប់រំដែរឬទេ ។ អរុណទុកចិត្តឪពុកម្តាយរបស់គាត់ ហើយអរុណចង់បានការជួយគាំទ្រពីពួកគាត់ ។

តើអរុណ និងគ្រួសាររបស់គាត់គួរពិចារណាវិធានច្បាប់អ្វីនៅក្នុងករណីនេះ?

# តើមានជម្រើសផ្សេងទៀតអ្វីខ្លះនៅក្នុងការថែទាំសុខភាព?

- ការសម្រេចចិត្តរបស់ជនពិការដោយមានការជួយគាំទ្រពីអាណាព្យាបាល
- ទម្រង់បែបបទសម្រាប់អនុញ្ញាតឲ្យគេចែកចាយព័ត៌មានផ្ទាល់ខ្លួន
  (“HIPAA” Release of Information Form )
- លិខិតអនុញ្ញាតប្រគល់សិទ្ធិសម្រេចចិត្តទាក់ទងនឹងសេវាថែទាំសុខភាព
  (Health Care Proxy)



*HIPAA = Health Insurance Portability and Accountability Act of 1996*

# សេណារីយ៉ូទី ២

តារាមានពិការភាពខាងសតិបញ្ញាដោយសារខូចប្រព័ន្ធបញ្ញាក្នុងខួរក្បាល (cerebral palsy) និងមានពិការភាពផ្នែកការសិក្សា (learning disability) ។ នាងមានអាយុ ២០ ឆ្នាំ។ ថ្មីៗនេះ វេជ្ជបណ្ឌិតរបស់នាងបានប្រាប់នាងថា នាងត្រូវការសេវាវះកាត់ ។ ពាក្យពេចន៍ខាងវិស័យពេទ្យដែលវេជ្ជបណ្ឌិតបានប្រើនោះ បានធ្វើឱ្យនាងវង្វេងវង្វាន់ ហើយនាងចង់ឲ្យគេជួយពន្យល់នាងឲ្យយល់សេចក្តី និងចង់បានចម្លើយចំពោះសំណួររបស់នាង ។ តារាក៏ព្រួយបារម្ភផងដែរថាតើនឹងមានអ្វីកើតឡើងប្រសិនបើមានផលវិបាកនៅក្នុងអំឡុងពេលនៃការវះកាត់នោះ ដែលវានឹងធ្វើឱ្យនាងមិនអាចសម្រេចចិត្តដោយខ្លួនឯងបាន ទាក់ទងនឹងសេវាថែទាំសុខភាព ។

តើតារា និងគ្រួសាររបស់នាងគួរពិចារណាវិធានច្បាប់អ្វីនៅក្នុងករណីនេះ?

# តើមានជម្រើសដទៃទៀតអ្វីខ្លះទាក់ទងនឹងការគ្រប់គ្រងប្រាក់កាស?



- ការសម្រេចចិត្តដែលមានការគាំទ្រ
- លិខិតផ្ទេរសិទ្ធិសម្រេចចិត្តទៅឲ្យបុគ្គលជាតំណាងដែលគេអាចប្រើការបានយូរអង្វែង (Durable Power of Attorney)
- បុគ្គលជាតំណាងដែលមានសិទ្ធិក្នុងការគ្រប់គ្រងប្រាក់កាស (ទាំងទទួលនិងចំណាយ) (Representative Payee)

# សេណារីយ៉ូទី ៣

សារុន មានជំងឺអូទីស្សឹម (ដែលមានចរិតទុយមុយ) ហើយពេលនេះគាត់មានអាយុ ២១ ឆ្នាំ ។ គ្រួសាររបស់គាត់បានជួយគាត់ក្នុងការដាក់ពាក្យដើម្បីសុំប្រាក់ឧបត្ថម្ភពីកម្មវិធីសន្តិសុខសង្គម (Social Security) ហើយគេបានរកឃើញថា គាត់មានសិទ្ធិទទួលប្រាក់ចំណូលបន្ថែម (SSI) ។ សព្វថ្ងៃគាត់មិនអាចនិយាយកើតទេ ប៉ុន្តែគាត់កំពុងរៀនរបៀបទាក់ទងជាមួយអ្នកដទៃដោយប្រើ iPad ។ គាត់មិនធ្លាប់គ្រប់គ្រងប្រាក់កាសផ្ទាល់ខ្លួនរបស់គាត់ទេ ។

តើសារុន និងគ្រួសាររបស់គាត់គួរពិចារណាប្រើប្រាស់វិធានច្បាប់អ្វីនៅក្នុងករណីនេះ?

# ស្ថាប័ននិងឯកសារពាក់ព័ន្ធ

- https://supporteddecisions.org
- https://www.wearemass.org/supported-decision-making
- https://www.conexioneslatinx-ma.org
- https://www.dlc-ma.org



# អ្នកអាចសួរសំណួរនៅពេលនេះ ឬនៅពេលក្រោយ

- មជ្ឈមណ្ឌលដើម្បីតំណាងសាធារណជន (Center for Public Representation)
  - Mona Igram, Megan Rusciano និង Morgan Whitlatch
  - លេខទូរស័ព្ទ 413-586-6024 ឬអ៊ីម៉ែល SDM@cpr-ma.org



*https://www.centerforpublicrep.org/*